# និទ្ឍិនិកាជាតក

## សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក

## បញ្ញាសនិបាត និទ្ឍិនិកាជាតកទី ១

## បិដកលេខ ៦១ ទំព័រ ១

## ព្រមទាំងអដ្ឋកថា

### ប្រែដោយ ខេមរៈ អចតារ

## និឡិនិកាជាតក[១]

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធដល់ការប្រលោមលួងលោមរបស់បុរាណទុតិយិកា ទើបត្រាស់ព្រះតម្រាស់នេះថា **ឧទ្ធយ្ហតេ ជនបទោ** ដូច្នេះជាដើម ។

ព្រះសាស្តា កាលនឹងត្រាស់ទើបសួរភិក្ខុនោះថា អ្នកត្រូវនរណាធ្វើឲ្យនឿយណាយ ? កាលភិក្ខុក្រាបទូលថា ត្រូវភរិយាចាស់ជាអ្នកធ្វើឲ្យនឿយណាយ ដូច្នេះ ទើបត្រាស់ថា ម្នាលភិក្ខុ ស្ត្រីនេះឯងជាអ្នកធ្វើសេចក្តីវិនាសដល់អ្នក (ក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន) សូម្បីក្នុងកាលមុន អ្នកអាស្រ័យស្ត្រីនេះហើយ សាបសូន្យចាកឈាន ជាអ្នកដល់សេចក្តីវិនាសយ៉ាងធំ ដូច្នេះ ទើបទ្រង់នាំអតីតនិទានមកថា

ក្នុងអតីតកាល ព្រះរាជាព្រះនាមព្រហ្មទត្ត ទ្រង់សោយរាជសម្បត្តិ ក្នុងក្រុងពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណមហាសាល ឈ្មោះថា ឧទិច្ចៈ លុះចម្រើនវ័យធំហើយ បានសិក្សាសិល្បសាស្ត្រចប់សព្វគ្រប់អស់ហើយ បួសជាឥសីធ្វើឈាននិងអភិញ្ញាឲ្យកើតឡើងហើយ ក៏សម្រេចការនៅអាស្រ័យក្នុងហិមវន្តប្រទេស ។ ព្រោះហេតុដូច្នោះ ដោយន័យដូចដែលបានពោលមកហើយ ក្នុងអលម្ពុសាជាតកនោះឯង មេម្រឹគមួយក្បាល់ បានតាំងគភ៌ហើយកើតកូន ។ កូននោះមានឈ្មោះថា ឥសិសិង្គៈ ។ បន្ទាប់មកបិតាបានចិញ្ចឹមគេឲ្យចម្រើនវ័យធំហើយទើបបួស បានសិក្សាការបរិកម្មកសិណ ។ មិនយូរប៉ុន្មាន គេក៏បានធ្វើឈាន និងអភិញ្ញាឲ្យកើតឡើង ទើបបានសម្រេចការនៅដោយសេចក្តីសុខដែលកើតអំពីឈាន បានជាអ្នកមានតបៈដ៏ខ្លាំងក្លា មានតបៈក៏កំពូល មានឥន្ទ្រិយដែល

---

១. ព្រះត្រៃបិដកខ្មែរថា នឡិនិកាជាតក ។

ឈ្មោះបានយ៉ាងល្អ ។ ព្រោះតេជះនៃសីលរបស់តាបសនោះ ឋានសក្កទេវរាជទើបកម្រើក ញាប់ញ័រ សក្កទេវរាជក៏ប្រមើលមើល បានជ្រាបដល់ហេតុ បានគិតថា យើងនឹងប្រើឧបាយ ដើម្បីទម្លាយសីលរបស់តាបសនេះឲ្យបាន ទើបហាមភ្លៀងមិនឲ្យធ្លាក់ ក្នុងកាសិករដ្ឋ ទាំងមូល រហូត ៣ ឆ្នាំ ។ ដែនទាំងមូលហាក់ដូចជាត្រូវភ្លើងឆេះហើយ ។ កាលស្រូវសំណាប មិនបរិបូណ៌ ពួកមនុស្សត្រូវទុព្ភិក្ខភ័យបៀតបៀន ទើបប្រជុំគ្នាត្រង់ព្រះលានហ្លួង ។ លំដាប់ នោះ ព្រះរាជាប្រថាប់ឈរនៅត្រង់ប្រហោងបង្អួច ត្រាស់សួរមនុស្សពួកនោះថា មានរឿងអ្វី ? ពួកមនុស្សទាំងនោះ នាំគ្នាក្រាបទូលថា បពិត្រមហារាជ កាលភ្លៀងមិនធ្លាក់រហូត ៣ ឆ្នាំ ដែនទាំងមូលក៏ក្តៅហែង ហើយក្រាបទូលទៀតថា បពិត្រព្រះសម្មតិទេព សូមព្រះអង្គចូរឲ្យ ភ្លៀងធ្លាក់ ។ ព្រះរាជាសូម្បីនឹងសមាទានសីល រក្សាឧបោសថ ក៏ទ្រង់មិនអាចនឹងឲ្យភ្លៀង ធ្លាក់ចុះបាន ។ ក្នុងកាលនោះ សក្កទេវរាជ ស្តេចចូលទៅកាន់បន្ទប់ដែលប្រកបដោយសិរី របស់ព្រះរាជាអង្គនោះ ក្នុងវេលាទៀបភ្លឺ ទ្រង់ធ្វើពន្លឺដ៏ភ្លឺថែងចាំងហើយ បានប្រថាប់ឈរនៅ កណ្តាលវេហា ។ ព្រះរាជាទតព្រះនេត្រឃើញពន្លឺនោះហើយ ត្រាស់សួរថា អ្នកជានរណា ? សក្កទេវរាជត្រាស់តបថា យើងជាសក្កទេវរាជ ។ ព្រះរាជាត្រាស់សួរថា ព្រះអង្គយាងមក ប្រាថ្នាអ្វី ? សក្កទេវរាជត្រាស់ថា មហារាជអើយ ! ភ្លៀងក្នុងដែនរបស់ព្រះអង្គធ្លាក់ឬទេ ? ព្រះរាជាត្រាស់ថា មិនធ្លាក់ទេ ។ សក្កទេវរាជត្រាស់សួរថា ព្រះអង្គទ្រង់ជ្រាបហេតុដែល ភ្លៀងមិនធ្លាក់ឬទេ ? ព្រះរាជាត្រាស់ថា មិនជ្រាបទេ ។ សក្កទេវរាជទើបត្រាស់បញ្ជាក់ថា មហារាជ ! ក្នុងហិមវន្តប្រទេស មានតាបសឈ្មោះឥសិសិង្គៈអាស្រ័យនៅ ។ តាបសនោះ មានតបៈដ៏ខ្លាំងក្លា មានឥន្ទ្រិយដែលឈ្មោះយ៉ាងល្អក្រៃលែង កាលភ្លៀងធ្លាក់ចុះមកជានិច្ច លោកក្រោធហើយសម្លឹងមើលអាកាស ព្រោះដូច្នោះ ភ្លៀងទើបមិនធ្លាក់ ។ ព្រះរាជាត្រាស់ សួរថា ឥឡូវនេះ នឹងគប្បីធ្វើយ៉ាងណាល្អក្នុងរឿងនេះ ? សក្កទេវរាជត្រាស់ថា កាលទម្លាយ

តបៈរបស់តាបសនោះបាន ភ្លៀងនឹងធ្លាក់ចុះមកវិញ ។ ព្រះរាជាត្រាស់សួរថា អ្នកណានឹងអាចទម្លាយតបៈរបស់តាបសនោះបាន ។ សក្កទេវរាជត្រាស់ប្រាប់ថា មហារាជ ព្រះរាជធីតាព្រះនាមនិឡិនិការបស់ព្រះអង្គនេះឯងទើបជាអ្នកអាច ព្រះអង្គចូរឲ្យមនុស្សហៅនាងមកហើយត្រាស់បញ្ជាថា បុត្រីចូរទៅកាន់ស្ថានទីឈ្មោះនេះហើយ ចូរទម្លាយតបៈរបស់តាបសឲ្យបាន ។ សក្កទេវរាជបង្គាប់ព្រះរាជាយ៉ាងនោះហើយ ស្តេចក៏បានទៅកាន់ទីលំនៅរបស់ព្រះអង្គវិញ ។ ក្នុងថ្ងៃស្អែក ព្រះរាជាទ្រង់ប្រឹក្សាជាមួយនឹងពួកអាមាត្យ ហើយត្រាស់បញ្ជាឲ្យហៅ ព្រះរាជធីតាមក ហើយត្រាស់ព្រះគាថាដំបូងថា

**ម្នាលនាងនិឡិនិកា ជនបទក្តៅស្ងួត ទាំងដែន ក៏វិនាស ចូរនាងមក ចូរនាងទៅញ៉ាំងព្រាហ្មណ៍ (អ្នកធ្វើនូវសេចក្តីវិនាស) ដល់អញនោះ ឲ្យមកលុះអំណាចរបស់ខ្លួន ។**

ព្រះរាជធីតានោះស្តាប់គាថានោះហើយ ទើបត្រាស់គាថាទី ២ តបថា

**បពិត្រព្រះរាជា ខ្ញុំម្ចាស់អត់ទ្រាំសេចក្តីលំបាកពុំបាន ខ្ញុំម្ចាស់នឹងទៅកាន់ព្រៃ ដែលមានដំរីអាស្រ័យ ដូចម្តេចបាន ។**

លំដាប់នោះ ព្រះរាជាបានត្រាស់ ២ គាថា ទៀតថា

**ម្នាលនាងនិឡិនិកា នាងចូរទៅកាន់ជនបទដ៏ស្តុកស្តម្ភ ហើយទៅដោយដំរីផង ដោយរថផង ដោយយាន (ទូក) ដែលគេគាបដោយឈើផង យ៉ាងនេះចុះ ។**

**ម្នាលខត្តិយានី ចូរនាងយកដំរី សេះ រថ និងថ្មើរជើង ទៅចុះ ចូរនាងនាំ ព្រាហ្មណ៍ឥសីសិង្គៈនោះ មកកាន់អំណាច (ខ្លួន) ដោយសម្បុរ និងរូបឆោមរបស់នាង ។**

*ព្រះរាជាអង្គនោះ ត្រាស់ព្រះតម្រាស់ដែលមិនគួរនឹងត្រាស់ជាមួយព្រះរាជធីតា យ៉ាងនោះ ក៏ព្រោះប្រាថ្នានឹងរក្សាដែន ។ សូម្បីព្រះរាជធីតានោះ ក៏ទូលទទួលតបថា ល្អ ។ លំដាប់នោះ ព្រះរាជាទ្រង់បានព្រះរាជទានរបស់របរដែលគួរព្រះរាជទានទាំងអស់ដល់អាមាត្យ ទ្រង់បញ្ជាព្រះរាជធីតាទៅជាមួយពួកអាមាត្យ ។ អាមាត្យទាំងឡាយនាំព្រះរាជធីតាទៅដល់បច្ចន្តជនបទហើយ ឲ្យតាំងបន្ទាយសម្រាកក្នុងជនបទនោះ ឲ្យលើកព្រះរាជធីតានោះឡើងហើយ ចូលទៅកាន់ហិមវន្តប្រទេស ដោយផ្លូវដែលព្រានព្រៃចង្អុលបង្ហាញប្រាប់ ក្នុងវេលាព្រឹក ក៏ដល់ទីជិតអាស្រមបទរបស់តាបសនោះ ។*

*ក្នុងខណៈនោះ ព្រះពោធិសត្វឲ្យបុត្រនៅចាំអាស្រមបទ ខ្លួនឯងត្រូវចូលទៅកាន់ព្រៃ ដើម្បីស្វែងរកផលាផល ។ ពួកព្រានព្រៃមិនទៅកាន់អាស្រមបទទេ តែឈរនៅត្រង់ទីដែលជាទីនៅរបស់តាបសនោះ កាលនឹងសម្តែងទីនៅនោះដល់ព្រះនាងនិឡិនិកា ទើបពោលពាក្យ ២ គាថា ថា*

***នុ៎ះ ប្រាកដជាអាស្រមរបស់តាបស ឈ្មោះឥសីសិង្គៈ ជាទីគួររីករាយ មានដើមចេកជាទង់ ជាគ្រឿងសម្គាល់ មានដើមស្មាច់ដុះព័ទ្ធជុំវិញ ។ នុ៎ះ ភ្លើងដែលឥសីសិង្គៈនោះ តាក់តែង (ដោយឈាន) នុ៎ះ ផ្សែងដែលឃើញប្រាកដ ខ្ញុំសម្គាល់ថា ឥសីសិង្គៈ អ្នកមាន ឫទ្ធិច្រើន មិនញ៉ាំងភ្លើងឲ្យសាបសូន្យទេ ។***

*ចំណែកពួកអាមាត្យ នាំគ្នាឡោមព័ទ្ធអាស្រមក្នុងវេលាដែលព្រះពោធិសត្វចូលទៅកាន់ព្រៃ ក៏នាំគ្នាតាំងកងពលរក្សា ឲ្យព្រះរាជធីតាក្លែងភេទជាឥសី យកសំពត់សំបកឈើពណ៌មាសប្រភេទខ្លះធ្វើជាសំពត់ស្លៀកនិងសំពត់ដណ្តប់ ប្រដាប់ដោយគ្រឿងអលង្ការគ្រប់យ៉ាងហើយ ឲ្យព្រះរាជធីតាកាន់យកកូនឃ្លីដែលវិចិត្រចងដោយខ្សែអំបោះ បញ្ជូនចូលទៅ*

*កាន់អាស្រមបទ ខ្លួនឯងនាំគ្នាឈររក្សានៅខាងក្រៅ ។ ព្រះរាជធីតានោះលេងកូនឃ្លីនោះ បណ្តើរៗ ក៏បំពារបំពានដល់ទីបំផុតរបស់ទីចង្ក្រម ។ ខណៈនោះ ឥសិសិង្គតាបស កំពុងអង្គុយត្រង់ទីជិតស៊ុមទ្វារបណ្ណសាលា ។ តាបសនោះក្រឡេកមើល ឃើញស្ត្រីនោះកំពុងដើរមក ក៏ភិតភ័យ ក្រោកឡើងហើយចូលទៅកាន់បណ្ណសាលា ។ សូម្បីព្រះរាជធីតានោះ ក៏ទៅកាន់ទ្វារបណ្ណសាលារបស់តាបសនោះហើយ ក៏លេង (កូនឃ្លី) តទៅទៀត ។*

*ព្រះសាស្តា កាលនឹងប្រកាសសេចក្តីនោះឲ្យក្រៃលែងជាងនោះទៀត ទើបបានត្រាស់គាថាទាំង ៣ នេះថា*

***ឥសីសិង្គៈ បានឃើញនាងនិឡិនិកានោះ ពាក់កុណ្ឌលកែវមណី កំពុងដើរមក ក៏ភិតភ័យ ចូលទៅកាន់អាស្រមដែលប្រក់ដោយស្លឹក ។***

***ឯនាងនិឡិនិកានោះ ក៏បង្ហាញនូវអវយវៈ ទាំងឡាយផង បញ្ចេញនូវកេរ្តិ៍ខ្មាស់ដ៏កំបាំងផង ហើយលេងកូនឃ្លី ក្បែរទ្វារអាស្រមនៃ ឥសីសិង្គៈនោះ ។***

***អ្នកមានជដា (ឥសីសិង្គៈ) នៅក្នុងបណ្ណាសាលា ឃើញនាងនិឡិនិកានោះ កំពុងលេងចេញអំពីអាស្រមមកនិយាយពាក្យនេះថា***

*ព្រោះដូច្នោះ ទើបពោលថា ឥសិសិង្គតាបសចេញ (អំពីអាស្រម) ហើយពោលពាក្យនេះថា*

***ម្នាលអ្នកដ៏ចម្រើន ឈើរបស់អ្នកនោះ ឈ្មោះអ្វី ដែលមានផ្លែបែបនេះ សូម្បីអ្នកបោះទៅក្នុងទីឆ្ងាយហើយ ក៏វិលត្រឡប់មកវិញ មិនទៅចោលអ្នក ។***

លំដាប់នោះ ព្រះរាជធីតានោះ កាលនឹងប្រាប់ទើបបានពោលគាថានេះ ដល់តាបសនោះថា

**បពិត្រតាបសដ៏ប្រសើរ ផ្លែបែបនេះ នៃឈើណា សូម្បីខ្ញុំបោះទៅក្នុងទីឆ្ងាយ ក៏ត្រឡប់មកវិញ មិនទៅចោលខ្ញុំទេ ឈើបែបនោះ មានក្នុងទីជិត អាស្រមនៃខ្ញុំ នាភ្នំគន្ធមាទន៍ ។**

ចំណែកតាបសនោះបានជឿហើយ កាលនឹងធ្វើបដិសណ្ឋារកិច្ចដោយសម្គាល់ថា អ្នកនោះជាតាបស ទើបពោលគាថានេះថា

**អ្នកដ៏ចម្រើនចូរមកកាន់អាស្រមនេះចុះ ចូរបរិភោគអាហារចុះ ចូរទទួលថ្នាំសម្រាប់លាបជើងផង ភក្សាហារផង ខ្ញុំជូន (ដល់អ្នក) នេះអាសនៈ អ្នកដ៏ចម្រើន ចូរអង្គុយលើអាសនៈនេះ អ្នកដ៏ចម្រើនចូរពិសាមើមឈើ និងផ្លែឈើក្នុងទីនេះចុះ ។**

តាបសបានឃើញអវយវៈដែលបិទបាំងនៃសរីរៈ របស់មាតុគ្រាម ព្រោះលោកមិនធ្លាប់ឃើញអំពីកាលមុន ទើបសម្គាល់ថា នុ៎ះជាដំបៅ ហើយ ពោលយ៉ាងនេះថា

**អ្វីនេះ កំពុងល្អ (ដូចមាត់ខ្យងបៀ) នៅត្រង់ចន្លោះភ្លៅរបស់អ្នក ប្រាកដដូចជាវត្ថុមានពណ៌ខ្មៅ ៗ ខ្ញុំសួរហើយ អ្នកចូរប្រាប់សេចក្ដីនុ៎ះ អវយវៈដ៏ឧត្តម (លិង្គ) របស់អ្នកលិចចូលទៅក្នុងស្រោម (សរីរៈ) ឬ ។**

លំដាប់នៅ ព្រះរាជធីតានោះ កាលនឹងបោកបញ្ឆោតតាបសនោះ ទើបពោល ២ គាថា ថា

**ខ្ញុំត្រាច់ទៅកាន់ទីស្វែងរកមើមឈើ ផ្លែឈើ ក្នុងព្រៃ បានជួបខ្លាឃ្មុំមានរូបដ៏សម្បើម ខ្លាឃ្មុំនោះ ស្ទុះមកសង្គ្រប់ខ្ញុំដោយរហ័ស ផ្ដួលខ្ញុំ ហើយខាំដកយកអវយវៈដ៏ឧត្តមទៅ ។**

***ដំបៅនោះឯង ឈឺពើតផង រមាស់ផង ខ្ញុំមិនបានសេចក្តីសុខ សព្វ ៗ កាលទេ អ្នកដ៏ចម្រើន អាចនាំចេញនូវរោគរមាស់នេះចេញបាន អ្នកដ៏ចម្រើនដែលខ្ញុំអង្វរហើយ សូមធ្វើនូវ ប្រយោជន៍ដល់ព្រាហ្មណ៍ ។***

*តាបសនោះ ស្តាប់ពាក្យមុសារបស់ព្រះរាជធីតានោះថាជាពាក្យពិត ទើបគិតថា បើសេចក្តីសុខយ៉ាងនេះនឹងមានដល់អ្នកសោត ខ្ញុំនឹងធ្វើឲ្យ បានសម្ទឹងមើលត្រង់នោះ ហើយ ពោលគាថាបន្ទាប់ទៅថា*

***ដំបៅរបស់អ្នកមានសភាពដ៏ជ្រៅ មានសម្បុរក្រហម មិនស្អុយទេ គ្រាន់តែមានក្លិន ខ្មោះ (បន្តិចៗ) ហើយថែមទាំងធំផង ខ្ញុំនឹងប្រកបដោយថ្នាំជុស លាបឲ្យអ្នកបន្តិចមើល ដើម្បីនឹងឲ្យអ្នកដ៏ចម្រើនបានសេចក្តីសុខស្រួល ។***

*លំដាប់នោះ ព្រះនាងនិឡិនិកាទើបត្រាស់គាថា ថា*

***បពិត្រតាបសដ៏ប្រសើរ ការប្រកបដោយមន្តទាំងឡាយ ក៏មិនត្រូវ ការប្រកបដោយថ្នាំ ជុសទាំងឡាយក៏មិនត្រូវ ឱសថទាំងឡាយក៏មិនត្រូវ អវយវៈណារបស់លោកដ៏ទន់ ៗ ចូរលោកនាំចេញនូវរោគរមាស់ដោយអវយវៈនោះ ទើបខ្ញុំមានសេចក្តីសុខស្រួលតទៅ ។***

*តាបសនោះ កំណត់ថា មនុស្សនេះនិយាយពិត មិនដឹងឡើយថា សីលនឹងដាច់ ឈាននឹងសាបសូន្យ ដោយមេថុនសំសគ្គៈ កាលព្រះរាជធីតានោះពោលថា ជាភេសជ្ជៈ ដូច្នេះ ព្រោះការមិនស្គាល់មេថុនធម្ម ហេតុដែលខ្លួនមិនធ្លាប់បានឃើញមាតុគ្រាមក្នុងកាល មុន ទើបសេពមេថុនធម្ម ក្នុងពេលនោះឯង សីលរបស់តាបសនោះក៏ដាច់ ឈានក៏វិនាស ។ តាបសនោះធ្វើការរួមសង្វាស ២, ៣ គ្រា ក៏នឿយហត់ ទើបចេញទៅកាន់ស្រះងូតទឹករម្ងាប់*

ការនៀយហត់ហើយ ត្រឡប់មកអង្គុយក្នុងបណ្ណសាលា ដល់ថ្នាក់សូម្បីយ៉ាងនោះហើយ ក៏សម្គាល់មនុស្សនោះថា ជាតាបសទៀត កាលនឹងសួរដល់ទីនៅ ទើបពោលគាថា ថា

អាស្រមរបស់អ្នកដ៏ចម្រើន នៅខាងណាអំពីទីនេះ ម្នាលអ្នកដ៏ចម្រើន អ្នកអភិរម្យក្នុងព្រៃដែរឬ អ្នកមានមើមឈើ ផ្លែឈើច្រើនដែរឬ សត្វសាហាវទាំងឡាយ មិនបៀតបៀនអ្នកដ៏ចម្រើនទេឬ ។

លំដាប់នោះ ព្រះនាងនិឡិនិកាបានត្រាស់ ៤ គាថា ថា

អាស្រមរបស់ខ្ញុំជាទីគួររីករាយ (នៅ) ក្បែរឆ្នេរនៃស្ទឹងឈ្មោះខេមា ដែលហូរទៅអំពីព្រៃហិមវន្ត នាទិសខាងជើងត្រង់អំពីទីនេះ ធ្វើដូចម្តេចហ្ន៎ អ្នកដ៏ចម្រើន គប្បីឃើញអាស្រមរបស់ខ្ញុំ ។

(ទៀបអាស្រមរបស់ខ្ញុំ) មានដើមស្វាយ រាំងភ្នំ ទន្ទាប់ ព្រីង រាជព្រឹក្ស ច្រនៀង មានផ្ការីកស្គុះស្គាយ ធ្វើដូចម្តេចហ្ន៎ អ្នកដ៏ចម្រើនគប្បីឃើញអាស្រមរបស់ខ្ញុំ ដែលមានកិន្នរច្រៀងពីរោះ ដោយជុំវិញ ។

ក្នុងទីជិតអាស្រមរបស់ខ្ញុំនុ៎ះ មានដើមត្នោតទាំងឡាយផង មើមឈើទាំងឡាយផង ផ្លែឈើទាំងឡាយផង ធ្វើដូចម្តេចហ្ន៎ ទើបអ្នកដ៏ចម្រើនគប្បីឃើញ នូវអាស្រមរបស់ខ្ញុំ ដែលប្រកបដោយពណ៌ និងក្លិន ដែលប្រកបដោយភូមិភាគទាំងឡាយ (ដ៏រាបស្មើ) នោះ ។

ផ្លែឈើទាំងឡាយផង មើមឈើទាំងឡាយផង មានគរគោក ក្នុង អាស្រមនេះ ប្រកបដោយពណ៌ ក្លិន និងរស តែពួកព្រានព្រៃ តែងមកកាន់ប្រទេសនោះ កុំឲ្យពួកវាលួចមើមឈើ និងផ្លែឈើរបស់ខ្ញុំ អំពីអាស្រមនោះឡើយ ។

*តាបសបានស្តាប់ដូច្នោះហើយ ដើម្បីនឹងឃាត់ព្រះរាជធីតាទុក រហូតបិតារបស់ខ្លួនត្រឡប់មក ទើបពោលគាថាថា*

***បិតារបស់ខ្ញុំ ទៅកាន់ទីស្វែងរកមើមឈើ ផ្លែឈើ នឹងមកក្នុងកាលល្ងាច ឥឡូវនេះ ចាំបិតា មកអំពីទីស្វែងរកមើមឈើ និងផ្លែឈើសិន សឹមយើងទាំងពីរនាក់ ទៅកាន់អាស្រមនោះ ។***

*លំដាប់នោះ ព្រះរាជធីតានោះ គិតហើយថា តាបសនេះមិនស្គាល់យើងជាស្ត្រី ព្រោះលោកចម្រើនវ័យធំឡើងតែនៅក្នុងព្រៃប៉ុណ្ណោះ តែបិតារបស់តាបសនោះ ល្មមឃើញយើងហើយនឹងដឹងភ្លាម លោកគង់នឹងសួរថា នាងមកធ្វើអ្វីក្នុងទីនេះ ហើយគង់នឹងយករំពាត់វាយយើង សូម្បីសីសៈរបស់យើងក៏នឹងត្រូវបែក យើងគួរនឹងចេញទៅ ក្នុងវេលាដែលបិតារបស់តាបសនៅមិនទាន់មកល្អជាង ការងាររបស់យើង ក៏សម្រេចហើយ ។ ព្រះរាជធីតានោះកាលនឹងប្រាប់ឧបាយនៃការមកដល់តាបសនោះ ទើបពោលគាថាដទៃទៀតថា*

***មានពួកព្រាហ្មណ៍ជាឥសី និងពួកព្រះរាជាជាឥសីដទៃទៀតជាច្រើន ដែលជាមនុស្សត្រឹមត្រូវ នៅក្បែរផ្លូវជាលំដាប់ ចូរអ្នកសួររកអាស្រមខ្ញុំនឹងឥសីទាំងនោះចុះ ឥសីទាំងនោះ នឹងនាំអ្នកទៅឯសម្នាក់ខ្ញុំ (មិនខាន) ។***

*ព្រះរាជធីតានោះ ធ្វើឧបាយដើម្បីគេចទៅយ៉ាងនេះហើយ ចេញអំពីបណ្ណសាលាហើយ ពោលនឹងតាបសដែលកំពុងសម្លឹងមើលនោះថា លោកត្រឡប់ទៅចុះ ហើយបានទៅកាន់សំណាក់របស់ពួកអាមាត្យ ដោយផ្លូវដែលមកនោះឯង ។ ពួកអាមាត្យទាំងនោះ បាននាំព្រះរាជធីតានោះទៅកាន់បន្ទាយហើយ ក៏ទៅដល់ក្រុងពារាណសីដោយលំដាប់ ។ ក្នុងថ្ងៃនោះឯង សូម្បីសក្កទេវរាជក៏ទ្រង់សប្បាយចិត្ត បានញុំាងភ្លៀងឲ្យធ្លាក់យ៉ាងជោកជាំ ក្នុងដែន*

ទាំងមូល ។ បន្ទាប់ពីនោះមក ជនបទក៏មានភិក្ខាបរិបូណ៌ ។ ក្នុងពេលដែលព្រះរាជធីតានោះត្រឡប់ទៅហើយប៉ុណ្ណោះ សេចក្ដីក្ដៅក្រហាយក៏កើតឡើង ក្នុងរាងកាយរបស់ឥសិសិង្គតាបស ។ តាបសនោះ មានចិត្តរវើរវាយ ចូលទៅកាន់បណ្ណសាលា យកសំពត់ដណ្ដប់រាងកាយហើយដេកទាំងសោកសៅ ។

ក្នុងវេលាល្ងាច ព្រះពោធិសត្វត្រឡប់មកមិនបានឃើញបុត្រ ទើបគិតថា គេទៅទីណាហ្ន៎ ហើយក៏ដាក់អម្រែកចូលទៅកាន់បណ្ណសាលា ឃើញគេកំពុងដេក យកដៃស្ទាបខ្នង សួរថា កូន កើតអីហ្នឹង ហើយបានពោល ៣ គាថា ថា

***ឧសក៏អ្នកមិនពុះ ទឹកក៏អ្នកមិនដង ទាំងភ្លើង ក៏អ្នកមិនបង្កាត់ ហេតុអ្វីបានជាអ្នកជ្រប់ស្រពោន ។***

***ម្នាលកូនសព្រហ្មចារី ឧសទាំងឡាយ អ្នកធ្លាប់តែពុះភ្លើង អ្នកធ្លាប់តែបង្កាត់ទាំងភ្លើងសម្រាប់អាំងក៏អ្នកចាត់ចែង តាំងក៏អ្នកធ្លាប់រៀបចំសម្រាប់អញ ទឹកក៏អ្នកធ្លាប់តែតម្កល់ទុកសម្រាប់អញ កាលពីមុន អ្នកជាមនុស្សប្រសើរ តែងរីករាយ ( ក្នុងអាស្រមនេះ) ។***

***(ឥឡូវនេះ) អ្នកមិនពុះឧស មិនដងទឹក មិនបង្កាត់ភ្លើង មិនស្ងោរវត្ថុសម្រាប់បរិភោគនៃកូនរបស់អញ ថ្ងៃនេះ អ្នកមិនហៅរកអញ អ្នកបានរបស់អ្វីឬ ឬក៏អ្នកកើតទុក្ខក្នុងចិត្តដូចម្ដេច ។***

តាបសនោះ ស្ដាប់ពាក្យរបស់បិតាហើយ កាលនឹងពោលដល់ហេតុការណ៍នោះឲ្យជ្រាប ទើបពោលថា

ជដិលជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរមកក្នុងទីនេះ ជាមនុស្ស គួរគេយកគន់ មានដងខ្លួនទ្រទេសទ្រទន់ មិនខ្ពស់ពេក មិនទាបពេក ញុំាងអាស្រមបទ ឲ្យភ្លឺសាយពាសពេញ ដោយសក់ទាំងឡាយ ដែលខ្មៅស្រិលដូចជាពណ៌នៃស្វាបកន្ទង់ របស់ជដិល ដ៏ចម្រើន (នោះ) ។

(ជដិលនោះ) មិនទាន់ដុះពុកមាត់នៅឡើយទេ ទើបនឹងបួសថ្មី ៗ មានទាំងរបស់មានសណ្ឋានដូចជើងបាត្រ ពាក់ត្រង់ករបស់គាត់ មានពកពីរជាគូ ភ្លឺបំព្រង ដូចជាផ្ទៃទន្ទាប់មាស ដុះក្បាំល្អត្រង់ទ្រូង ។

មុខជដិលនោះ គួរគេយកគន់ក្រៃពេក មានកំពូលនៃគ្រឿងប្រដាប់ ត្រចៀកទាំងឡាយសំយុងចុះ ឰដ៏ត្រចៀកទាំងឡាយ កាលមាណព (នោះ) ត្រាច់ទៅ គ្រឿងប្រដាប់នៃត្រចៀកទាំងនោះ ក៏រុងរឿងផ្ទេក ៗ ផង មានទាំងខ្សែសយ រុំព័ទ្ធផ្នួងសក់ ទាំងឡាយផង ។

មាណពនោះ មានគ្រឿងប្រដាប់ដទៃ ទៀតមានពន្លឺ ៤ ពណ៌គឺ ពណ៌ខៀវលឿង ក្រហម ស កាលបើមាណព ( នោះ) ដើរទៅគ្រឿងប្រដាប់ទាំងនោះ ញ័រ ៗ ដូចជាពួកនៃសត្វមេភ្លៀង ក្នុងពេលកំពុងភ្លៀង ។

(មាណពនោះ) មិនពាក់សង្វារស្មៅ យាប្ញូងទេ មិនប្រើប្រាស់សំពត់សំបកឈើទេ មិនប្រើប្រាស់សំពត់ដែលត្បាញដោយស្មៅដំណេកទន្សាយទេ គ្រឿងប្រដាប់ទាំងនោះជាប់នៅត្រង់ចន្លោះនៃស្មង ភ្លឺដូចជាផ្ទេកបន្ទោរ ដែលចាំងឰដ៏អាកាស ។

(មាណពនោះ មានគ្រឿងប្រដាប់ដេរជាសដោយសូត្រ) មិនមាន ស្នាមគ្រោតគ្រាតផង មិនមានទង (អាចម៍ដង្កូវ) ផង ចងព័ទ្ធត្រង់ចង្កេះ ពីត្រឹមផ្ចិតចុះទៅ ខាងក្រោម គ្រឿងប្រដាប់ទាំងនោះ ទុកជាឥតមានអ្វីប៉ះពាល់សោះ ក៏ធ្វើនូវល្បែងជានិច្ច គឺញ័ររវិចជាប្រក្រតី បពិត្របិតាដ៏ចម្រើនគ្រឿងប្រដាប់ទាំងនោះ ឈ្មោះថាផ្លៃឈើអ្វី ។

ផ្នូងសក់របស់មាណពនោះ ក៏គួរឲ្យចង់មើលក្រៃពេក (បើមើល) ជាងមួយរយដង (ក៏មិន អស់ចិត្ត) មានចុងង៉ខ្វង់ មានក្លិនក្រអូប (មាណពនោះ) មានសក់ក្បាលញែកជាពីរ សិត ញែកស្អាតបាត ធ្វើដូចម្ដេចហ្ន៎ នឹងបានឲ្យផ្នួងសក់ របស់ខ្ញុំល្អដូច្នោះផង ។

មាណពនោះ រំសាយសក់ក្នុងកាលណា ផ្នួងសក់ទាំងឡាយនោះ ក៏ប្រកបដោយពណ៌ ក្នុងកាលនោះ អាស្រមនេះ ក៏ក្លឺផ្សព្វផ្សាយទៅ (ដោយក្លិន) ដូចជាផ្កាឧប្បលខៀវ ដែលខ្យល់បក់ត្រូវដូច្នោះ ។

សម្បុររបស់មាណពនោះ គួរឲ្យចង់ មើលក្រៃពេក កាយរបស់មាណពនោះ មិនដូចជាកាយ របស់ខ្ញុំឡើយ កាយរបស់ មាណពនោះ កាលបើត្រូវខ្យល់បក់មក ផ្សព្វផ្សាយក្លិន ដូចជាព្រៃ ឈើ ដែលមានផ្ការីក ស្គុះស្គាយ ក្នុងខាងចុងនៃគិម្ហរដូវ ។

មាណពនោះ តែងទះនូវផ្លៃឈើ មានសភាព ដ៏វិចិត្រល្អរុងរឿង គួរឲ្យចង់មើល បោះទៅលើផែនដី ផ្លៃឈើនោះ រមែងត្រឡប់ មក រកដៃរបស់មាណពនោះវិញ បពិត្រ បិតាដ៏ចម្រើននោះជាផ្លៃឈើអ្វី ។

ធ្មេញទាំងឡាយ របស់មាណពនោះ ក៏គួរឲ្យចង់មើលក្រៃពេក ស្អាតស្មើដូចជាស័ង្ខ ដែលគេខាត់ យ៉ាងសំខាន់ កាលដែលគាត់ហាមាត់ឡើង តែងញុំាងចិត្តឲ្យជ្រះថ្លា ត្បិតមាណពនោះ មិនទំពាស៊ីនូវបន្លែ ដោយធ្មេញទាំងឡាយនោះទេ ។

សំដីរបស់មាណពនោះ និយាយ ឡើងមិនជាសំដីអាក្រក់ មិនក្ងាត់ ពីរោះ ស្រទន់ត្រង់ ៗ មិនរាយមាយ មិនព្រកោកកាក ជាសំដីញុំាងចិត្តឲ្យរីករាយ គួរចាប់ចិត្ត ដូចជាសំឡេង នៃសត្វករវិក យាសយំ ចិត្តរបស់ខ្ញុំត្រេកអរខ្លាំងណាស់ ។

(មាណពនោះ) មានសំឡេងមូល មានពាក្យមិនសូវ គ្បោះក្បាយពេកទេ មិនមែនជាអ្នក ខ្វល់ខ្វាយក្នុងការស្វាធ្យាយ (មន្ត) ដោយពិត ខ្ញុំចង់ឃើញមាណពនោះម្តងទៀត ត្បិត មាណព (នោះ) ជាមិត្តរបស់ខ្ញុំតាំងពីដម្បូងមក ។

ដំបៅ (ត្រង់ចន្ទៅភ្លៅរបស់មាណពនោះ) ជិតស្និទ្ធល្អ រលីងស្អាតសព្វអន្ទើ ក្រាស់ ក្បិល្អ ដូចជាផ្កាឈូកក្រពុំ មាណព (នោះ) គ្របសង្កត់ខ្ញុំដោយដំបៅនោះឯង សើយភ្លៅហើយគាបខ្ញុំដោយស្នេង ។

(ស្មើដូចមាស ដែល ផ្សាយចេញអំពីសរីរៈកាយ នៃមាណពនោះ) ភ្ញីត្រចះត្រចង់ ភ្ញីស្វាងរុងរឿង ភ្ញីផ្ទេក ៗ ដូចជាផ្ទេកបន្ទោរធ្មៀលធ្លាត់ លើអាកាស ដើមដៃទាំងពីរទន់ភ្លន់ មានរោមប្រហែលកេសរ ផ្កាអញ្ចន មាណពនោះ មានម្រាមដៃមូល ៗ ដំរិចត្រល្អ ។

ម្យ៉ាងទៀត (មាណពនោះ) មានអវយវៈតូចធំ មិនរដិបរដុប (ដោយមុននិងបូសជាដើម) ទេ មានរោមមិនវែងពេកទេ ឯក្រចករបស់ មាណពនោះ វែង ៗ មានចុងក្រហម ៗ (មាណពនោះ) មានរូបល្អ ឱបរិត (ខ្ញុំ) ដោយដើមដៃទាំងពីរដ៏ទន់ល្វន់ (ផ្គាប់ផ្គុនខ្ញុំ) ឲ្យរីករាយ ។

ដៃទាំងពីរ របស់មាណពនោះ ដូចជាប៉ុយឈើ មានរស្មីផ្ទេក ៗ មានបាតដៃមូល និងធរីវណ្ណស្រស់បំព្រង ដូចផ្ទៃកញ្ចក់ ជាវិការៈនៃមាស មាពណនោះពាល់ខ្ញុំ ដោយដៃទាំងពីរនោះហើយ ទៅពីទីនេះទៅ បពិត្របិតា មាណពនោះ ដុតរោលខ្ញុំ (ឲ្យក្តៅក្រហាយ) ដោយសម្ផស្សនៃដៃនោះ ។

មាណពនោះ ប្រហែលជាមិនដែលនាំទៅនូវវត្ថុមានទម្ងន់មួយខារី (មួយអំរែក) ទេ មាណព នោះ មិនដែលពុះឧសទាំងឡាយខ្លួនឯងទេ មាណពនោះ មិនដែលកាប់ឈើទាំងឡាយ ដោយកាំបិតទេ បានជាដៃរបស់មាណពនោះ មិនគ្រិនសោះ ។

មានខ្លាឃ្មុំមួយធ្វើមាណព នោះឲ្យដំបៅ គេបាននិយាយនឹងខ្ញុំថា សូមឲ្យអ្នកធ្វើខ្ញុំឲ្យបានសេចក្ដីសុខស្រួល ខ្ញុំក៏បាន ធ្វើគាត់ឲ្យបានសុខស្រួលដោយអវយវៈដ៏ឧត្តមនោះរបស់ខ្ញុំ បពិត្រឫសីដ៏ប្រសើរ មាណព នោះបាននិយាយប្រាប់ខ្ញុំថា ខ្ញុំបានសេចក្ដីសុខស្រួលហើយ ។

នេះកម្រាលនៃស្លឹកឈើទាល មានសភាពរាត់រាយ ដែលខ្ញុំនិងគេដេក ប្រកៀកប្រឱប លើគ្នា យើងទាំងពីរនាក់នោះអស់ កម្លាំងក៏ចុះងូតទឹក ហើយចូលទៅកាន់បណ្ណកុដិរឿយៗ ។

បពិត្របិតា ខ្ញុំមិនបានជួបនឹង ព្រហ្មចារីនោះ ដរាបណា មន្តទាំងឡាយមិនជាក់ច្បាស់ដល់ខ្ញុំក្នុងថ្ងៃនេះផង ខ្ញុំមិនពេញចិត្ត នឹងការបូជាភ្លើងផង មិនពេញចិត្តនឹងការបូជាយ័ញ្ញផង ទាំងមិនបរិភោគមើមឈើ និង ផ្លែឈើរបស់លោកផង ដរាបនោះ ។

បពិត្របិតា ចំណែកលោកជ្រាបច្បាស់ប្រាកដ ព្រហ្មចារី (នោះ) នៅក្នុងទិសណា បពិត្របិតា សូមលោកជូនខ្ញុំទៅឲ្យដល់ទិសនោះយ៉ាងឆាប់ កុំឲ្យខ្ញុំស្លាប់ក្នុងអាស្រម របស់លោកឡើយ ។

ត្បិតខ្ញុំបានឮថា ព្រៃ (ជាទីនៅនៃព្រហ្មចារី នោះ) មានផ្ការីកស្គុះស្គាយដ៏វិចិត្រ ហើយជាទីអឺងកងដោយបក្សី ជាទីដែលពួកបក្សីនៅ អាស្រ័យ (ជានិច្ច) បពិត្របិតា សូមលោកជូនខ្ញុំទៅឲ្យដល់ព្រៃនោះឆាប់ៗ មុនខ្ញុំនឹងលះជីវិត ក្នុងអាស្រម របស់លោក ។

*កាលតាបសនោះនិយាយរឿយនោះឯង ព្រះមហាពោធិសត្វ បានស្តាប់ពាក្យនោះ ហើយ ក៏ជ្រាបថា សីលរបស់តាបសនោះ ត្រូវស្ត្រីនោះទម្លាយឲ្យដាច់ ដូចនេះ កាលនឹង ពោលប្រៀនប្រដៅតាបសនោះ ទើបពោលគាថា ៦ គាថា ថា*

*(ព្រះមហាសត្វ...) សេចក្តីពិតថា បុគ្គលមិនគួរដល់នូវសេចក្តីអផ្សុក បែបនេះ ក្នុង ព្រៃដែលរុងរឿងដោយពន្លឺ ជាទីគឹកកងដោយពួកគន្ធព្វ និងស្រីទេពអប្សរ ជាទីនៅនៃឥសី ទាំងឡាយ ជាព្រៃមានតាំងពីយូរយារណាស់ហើយនេះឡើយ ។*

*មិត្តទាំងឡាយ មានខ្លះ មិនមានខ្លះ ជនទាំងឡាយគួរធ្វើនូវសេចក្តីស្រឡាញ់ ចំពោះញាតិ និងមិត្ត មនុស្សណាមិន ដឹងថា អាត្មាអញកើតមកពីណា មនុស្សនេះ គម្រក់ ត្រូវមាតុគ្រាមបង្វឹកបានទាំងថ្ងៃ ដោយហេតុអ្វី ។*

*ធម្មតាមិត្តទាំងឡាយ រមែងជាប់តគ្នា ដោយការនៅរួមរឿយៗ មិត្តនោះឯង រមែងលាកចិត្តដោយការមិនបាននៅរួមគ្នា របស់បុរស ដែលមិនបានទៅមករកគ្នា ។*

*បើអ្នក ឃើញនូវព្រហ្មចារី (នោះទៀត) បើអ្នកចរចាជាមួយនឹងព្រហ្មចារី (នោះទៀត) អ្នកនឹង បំផ្លាញនូវតបោគុណនេះ យ៉ាងឆាប់ មិនខាន ដូចជាសន្ទូងដ៏ល្អបរិបូណ៌ ដែលទឹកធំបំផ្លាញ ដូច្នោះ ។*

*បើអ្នកនឹងឃើញនូវ ព្រហ្មចារី (នោះ) ទៀត បើអ្នកចរចាជាមួយនឹងព្រហ្មចារី (នោះ) ទៀត អ្នកនឹងបំផ្លាញនូវតេជះរបស់សមណៈនេះ យ៉ាងឆាប់មិនខាន ដូចជាសន្ទូងល្អ បិរបូណ៌ ដែល ទឹកធំបំផ្លាញដូច្នោះ ។*

នៃកូនកូតទាំងឡាយនេះ តែងត្រាច់ទៅក្នុងមនុស្ស លោក ដោយបែបភាពនៃរូប ផ្សេង ៗ ជនអ្នកមានប្រាជ្ញា មិនត្រូវគប់រកនឹងកូតទាំងឡាយនោះឡើយ បុគ្គលជាអ្នកប្រព្រឹត្ត ធម៌ដ៏ប្រសើរ តែងវិនាសទៅ (ព្រោះដល់) នូវការជាប់ជំពាក់ (នឹងកូតបែបនោះឯង) ។

តាបសនោះ បានស្តាប់ពាក្យរបស់បិតាហើយកើតសេចក្តីភ័យខ្លាចថា ទើបតែជ្រាបថា ស្ត្រីនោះគឺនាងយក្ខិណី ទើបប្តូរចិត្តហើយ សូមខទោសឪពុកថា លោកឪពុក ខ្ញុំនឹងមិនសូម ទៅអំពីទីនេះ ឪពុកលើកទោសឲ្យខ្ញុំផង ។ សូម្បីព្រះពោធិសត្វនោះ លួងលោមឲ្យកូន សប្បាយចិត្តហើយ ទើបប្រាប់ដល់វិធីចម្រើនព្រហ្មវិហារថា មាណពតូច អ្នកមកទីនេះ អ្នក ចូរចម្រើនមេត្តា ករុណា មុទិតា និងឧបេក្ខាចុះ ។ តាបសនោះ បដិបត្តិតាមយ៉ាងនោះ ក៏ធ្វើ ឈាននិងអភិញ្ញាឲ្យកើតឡើងបានម្តងទៀត ។

ព្រះសាស្តា គ្រាទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ហើយ ទ្រង់ប្រជុំជាតក ។ ក្នុងវេលាចប់សច្ចៈ ឧក្កណ្ឋិតភិក្ខុ តាំងនៅក្នុងសោតាបត្តិផល ។ ព្រះរាជធីតាក្នុងកាលនោះ បានមកជាបុរាណទុតិយិកា ។ ឥសិសិង្គតាបស បានមកជា ឧក្កណ្ឋិតភិក្ខុ ចំណែកព្រះពោធិសត្វដែលជាបិតា គឺតថាគតនេះឯង ។

ចប់និឡិនិកាជាតក ។